PESTECH

# PESTECH

## ផេសថិក (ខេមបូឌា) ម.ក

## របាយការណ៍ត្រីមាស

សម្រាប់ត្រីមាសទីមួយនៃឆ្នាំហិរញ្ញវត្ថុដែលបានបញ្ចប់

នៅថ្ងៃទី ៣០ ខែ មិថុនា ឆ្នាំ ២០២១

PESTECH

## ព័ត៌មានហិរញ្ញវត្ថុសង្ខេប

| បរិយាយ | | ត្រីមាសទីមួយ ឆ្នាំ ២០២១ (លានរៀល) | ឆ្នាំ ២០២០ (លានរៀល) |
|---|---|---|---|
| **ស្ថានភាពហិរញ្ញវត្ថុ** | | | |
| ទ្រព្យសកម្មសរុប | | ១ ០៦០ ៨៩៧ | ១ ០១៦ ១១២ |
| បំណុលសរុប | | ៩៧៩ ៦០៩ | ៩៤៦ ១៥៥ |
| មូលធនសរុប | | ៨១ ២៨៨ | ៦៩ ៩៥៧ |
| **លទ្ធផលហិរញ្ញវត្ថុ** | | **ត្រីមាសទីមួយ ឆ្នាំ ២០២១ (លានរៀល)** | **ត្រីមាសទីមួយ ឆ្នាំ ២០២០ (លានរៀល)** |
| ចំណូលសរុប | | ៧៤ ៩៤៨ | ៤២ ៧០៩ |
| ចំណេញ/(ខាត) មុនបង់ពន្ធ | | (១៨៨) | ១ ៨២២ |
| ចំណេញ/(ខាត) ក្នុងការិយបរិច្ឆេទ | | (១ ២៩៥) | ៦២០ |
| លទ្ធផលលម្អិតក្នុងការិយបរិច្ឆេទ | | (៦៤៨) | (៤ ៥២១) |
| **អនុបាតហិរញ្ញវត្ថុ** | | **ត្រីមាសទីមួយ ឆ្នាំ ២០២១ (លានរៀល)** | **ឆ្នាំ ២០២០ (លានរៀល)** |
| អនុបាតសាធនភាព | | (0,0២%) | 7,៤៣% |
| អនុបាតសន្ទនីយភាព | អនុបាតចរន្ត | 0,៨៤ | 0,២៨ |
| | អនុបាតចរន្តលឿន | 0,៨១ | 0,២៤ |
| | | **ត្រីមាសទីមួយ ឆ្នាំ ២០២១ (លានរៀល)** | **ត្រីមាសទីមួយ ឆ្នាំ ២០២០ (លានរៀល)** |
| អនុបាតចំណេញភាព | អនុបាតចំណេញធៀបនឹងទ្រព្យសកម្ម | (0,១២%) | 0,0៦% |
| | អនុបាតចំណេញធៀបនឹងមូលធន | (១,៥៩%) | 0,៨៩% |
| | អនុបាតគម្លាតចំណេញដុល | ១៣% | ៧% |
| | អនុបាតគម្លាតចំណេញភាព | (១,៧៤%) | ១,៤៥% |
| | ចំណេញក្នុងមួយឯកតាមូលបត្រកម្មសិទ្ធិ (រៀល) | (0,៤៣) | 0,៨៧ |
| អនុបាទលទ្ធភាពបង់ការប្រាក់ | | 0,៩៧ | ១,៤0 |
| ភាគលាភក្នុងមួយឯកតាមូលបត្រកម្មសិទ្ធិ (ប្រសិនមាន) | | - | |
| អនុបាតហិរញ្ញវត្ថុសំខាន់ៗផ្សេងទៀត (ប្រសិនមាន) | | - | |

PESTECH

# សមាសភាពក្រុមប្រឹក្សាភិបាល



Paul Lim Pay Chuan

ប្រធានក្រុមប្រឹក្សាភិបាល



Lim Ah Hock

អភិបាល



Han Fatt Juan

នាយកប្រតិបត្តិ/ប្រធាននាយកប្រតិបត្តិ



Charles Tan Pu Hooi

អភិបាល



ដាវ អានសាន

អភិបាលឯករាជ្យ

PESTECH

# សេចក្តីថ្លែងរបស់ប្រធានក្រុមប្រឹក្សាភិបាល

ភាគហ៊ុនិក ជាទីរាប់អាន!

ខ្ញុំមានសេចក្តីសោមនស្សរីករាយជាខ្លាំងក្នុងការបង្ហាញទៅកាន់អ្នកទាំងអស់គ្នា នូវរបាយការណ៍ប្រចាំត្រីមាសទីមួយប្រចាំឆ្នាំ 2021 របស់ក្រុមហ៊ុន ផេសថិក (ខេមបូឌា) ម.ក ("PCL")។

នៅក្នុងអំឡុងត្រីមាសក្រោមការត្រួតពិនិត្យឡើងវិញ ពោលគឺក្នុងរយៈពេលចាប់ពី ខែកក្កដា រហូតដល់ ខែកញ្ញា ឆ្នាំ ២០២០ PCL អាចទ្រាំទ្រនឹងផលប៉ះពាល់នៃជំងឺរាតត្បាតសកលដែលជះឥទ្ធិពលទូទៅដល់ការធ្វើដំណើរជាអន្តរជាតិ និងសកម្មភាពដឹកជញ្ជូន។ ការអនុវត្តការងាររបស់យើងទទួលរងនូវការប៉ះពាល់ខ្លះៗ នៅពេលណាដែលមានតម្រូវការផ្នែកបច្ចេកទេសពីក្រុមជំនាញនៃអ្នកផ្គត់ផ្គង់ឧបករណ៍ធំៗអន្តរជាតិ។

ទោះបីជាយ៉ាងណាខ្ញុំមានទំនុកចិត្តដែល PCL មានក្រុមបុគ្គលិកក្នុងស្រុកដែលជាបុគ្គលិកមានសមត្ថភាពដែលអាចបំពេញភារកិច្ចចាំបាច់ទាំងអស់ដែលមាននៅក្នុងដៃក្នុងពេលដ៏លំបាកនេះ នៅខណៈពេលដែលឧស្សាហកម្មផ្សេងៗនៅលើពិភពលោកកំពុងពុះពារក្នុងការដំណើរការ។ ចំពោះរឿងនេះយើងខ្ញុំមានសំណាងដែលប្រតិបត្តិការរបស់យើងនៅកម្ពុជាមិនបានរងផលប៉ះពាល់គួរឱ្យកត់សម្គាល់ ដោយជំងឺរាតត្បាតសកលឡើយ ហើយ PCL នៅតែមានភាពអត់ធ្មត់ក្នុងការបន្តប្រតិបត្តិការអាជីវកម្មរបស់ខ្លួនក្រោមស្ថានភាពធម្មតាជាថ្មី ដែលបណ្តាលមកពីកូវីដ១៩។

យើងខ្ញុំមានសេចក្តីរីករាយដើម្បីជម្រាបជូនថា PCL បានបញ្ចប់គម្រោងដំបូងរបស់ខ្លួន ដែលទទួលបានប្រកបដោយភាពជោគជ័យតាមរយៈការសាងសង់ទីវាលពន្លឺព្រះអាទិត្យខ្នាតធំទំហំ ២០មេហ្គាវ៉ាត់ ដែលមានទីតាំងនៅខេត្តបារិតនៃប្រទេសកម្ពុជា និងការប្រើប្រាស់ក្នុងតំបន់។ ក្នុងដំណើរឆ្ពោះទៅមុខ កិច្ចខិតខំប្រឹងប្រែងនឹងត្រូវបានធ្វើឡើងដើម្បីជំរុញអោយមានការប្រើប្រាស់ថាមពលកកើតឡើងវិញ នៅក្នុងការផលិតអគ្គិសនី ជាពិសេសសម្រាប់តំបន់ដាច់ស្រយាល។

ក្រុមហ៊ុនបុត្រសម្ព័ន្ធរបស់យើងនៅក្នុងប្រទេសមីយ៉ាន់ម៉ាក៏កំពុងតែត្រៀមធ្វើសកម្មភាពផ្សេងៗ សម្រាប់ការចូលរួមគម្រោងក្នុងប្រទេសខណៈពេលដែលរង់ចាំការលើកស្ទួយនៃបំរែបំរួលការដាក់កំហិតនៃច្បាប់។ តាមរយៈផេសថិក (មីយ៉ាន់ម៉ា) លីមីតធីត ដែលជាក្រុមហ៊ុនបុត្រសម្ព័ន្ធ ១០០ភាគរយរបស់ PCL គ្រោងនឹងចាប់ផ្តើមគម្រោងហេដ្ឋារចនាសម្ព័ន្ធថាមពលអគ្គីសនីដែលដេញថ្លៃនៅក្នុងប្រទេសមីយ៉ាន់ម៉ាដើម្បីពង្រីកទីផ្សារ PCL នៅក្នុងតំបន់ឥណ្ឌូចិន។

ក្រុមហ៊ុនបានរក្សាទស្សនៈវិស័យដ៏វែងឆ្ងាយរបស់ខ្លួននៃការរីកដុះដាលនៃកំណើនវិជ្ជមាននៅក្នុងតំបន់ ជាពិសេសនៅក្នុងប្រទេសកម្ពុជា ហើយបានបន្តសាងសមត្ថភាពវិស្វកម្មនិងស្វែងរកមធ្យោបាយផ្សេងៗដើម្បីបន្ថែមសេវាកម្មទៅលើវិស័យហេដ្ឋារចនាសម្ព័ន្ធថាមពលអគ្គិសនីដែលបង្កើតឡើងសម្រាប់ប្រជាជាតិ និងប្រជាជននៅឥណ្ឌូចិន។

សូមអរគុណ!

ព្រះរាជាណាចក្រកម្ពុជា
ផេសថិក
(ខេមបូឌា) ម.ក
PESTECH (CAMBODIA)
PLC
KINGDOM OF CAMBODIA

Lim Pay Chuan

ប្រធានក្រុមប្រឹក្សាភិបាល

កាលបរិច្ឆេទ៖ ថ្ងៃទី ១១ ខែ វិច្ឆិកា ឆ្នាំ ២០២០

11 NOV 2020

PESTECH

# សេចក្តីថ្លែងរបស់នាយកប្រតិបត្តិ

ភាគហ៊ុនិក ជាទីរាប់អាន!

ផេសថិក (ខេមបូឌា) ម.ក ("PCL") នៅតែបន្តប្រតិបត្តិការក្នុងគ្រាលំបាកនេះដោយផ្តោតយ៉ាងខ្លាំងទៅលើការអនុវត្តគម្រោងដែលមាននៅក្នុងដៃក្នុងត្រីមាសទី ១ សម្រាប់ឆ្នាំហិរញ្ញវត្ថុ ២០២១ ។

ក្នុងអំឡុងត្រីមាសនេះ PCL បានធ្វើការលើទីវាលពន្លឺព្រះអាទិត្យខ្នាតធំទំហំ ២០មេហ្គាវ៉ាត់ ដែលមានទីតាំងនៅខេត្តបាវិតដោយបានបញ្ចប់ផ្នែកការរចនានិងគម្រោងវិស្វកម្ម។ ក្រុមការងារនឹងធ្វើការវាយតម្លៃសម្រាប់ការទិញសម្ភារៈ និងការរៀបចំទីតាំងរួមទាំងការងារស៊ីវិលជាបឋមនៅត្រីមាសបន្ទាប់។

ក្នុងពេលបច្ចុប្បន្ន ក្រុមការងាររបស់យើងមួយក្រុមទៀតកំពុងមមាញឹកក្នុងការអនុវត្តគម្រោងអនុស្ថានីយ៍រ៉ែមាសនៅតំបន់អូរខ្វារនៅខេត្តមណ្ឌលគីរី។ យើងរំពឹងថាគម្រោងនេះនឹងដំណើរការទៅមុខយ៉ាងលឿន និងមានគោលដៅបញ្ចប់នៅ ខែមេសា ឆ្នាំ ២០២១ ។

ក្រុមការងារផ្នែកបណ្តាញខ្សែបញ្ជូនក៏ត្រូវបង្កើតឡើងនៅដំណាក់កាលដំបូងនៃគម្រោងខ្សែបញ្ជូន ១៣០គីឡូម៉ែត ដែលបានប្រមូលទិន្នន័យលើបណ្តាញខ្សែ ពិសោធន៍ដី ការសិក្សាអំពីផលប៉ះពាល់បរិស្ថាននិងសង្គម។ ក្រុមការងារបានធ្វើការជាមួយអគ្គិសនីកម្ពុជាយ៉ាងជិតស្និទ្ធដើម្បីកំណត់ផ្លូវបណ្តាញ ដូច្នេះការអនុវត្តការងារនឹងប្រព្រឹត្តទៅយ៉ាងរលូន។

សរុបសេចក្តីមក យើងបានត្រៀមខ្លួនជាស្រេចក្នុងការបន្តប្រតិបត្តិការ ក្នុងអំឡុងពេលមានជំងឺរាតត្បាតសកលនេះដោយមានការប្តេជ្ញាថានឹងផ្តល់នូវសេវាកម្មល្អបំផុតរបស់យើងដល់អ្នកប្រើប្រាស់។

សូមអរគុណ!

ព្រះរាជាណាចក្រកម្ពុជា
ផេសធិក
(ខេមបូឌា) ម.ក
PESTECH (CAMBODIA)
PLC
KINGDOM OF CAMBODIA

Han Eatt Juan

ប្រធាននាយកប្រតិបត្តិ

កាលបរិច្ឆេទៈ ថ្ងៃទី ១១ ខែ វិច្ឆិកា ឆ្នាំ ២០២០

11 NOV 2020

PESTECH

# មាតិកា


ព័ត៌មានហិរញ្ញវត្ថុសង្ខេប ....... i
ក្រាហ្វិកអំពីព័ត៌មានហិរញ្ញវត្ថុសង្ខេប ....... ii
សមាសភាពក្រុមប្រឹក្សាភិបាល ....... iii
សេចក្តីថ្លែងរបស់ប្រធានក្រុមប្រឹក្សាភិបាល ....... iv
សេចក្តីថ្លែងរបស់នាយប្រតិបត្តិ ....... v

**ផ្នែកទី ១-ព័ត៌មានទូទៅពាក់ព័ន្ធនឹងក្រុមហ៊ុន**

ក. អត្តសញ្ញាណរបស់ក្រុមហ៊ុន

ខ. ប្រភេទអាជីវកម្ម

គ. ព្រឹត្តិការណ៍សំខាន់ប្រចាំត្រីមាស

**ផ្នែកទី ២ - ព័ត៌មានអំពីលទ្ធផលប្រតិបត្តិការធុរកិច្ច**

ក. លទ្ធផលប្រតិបត្តិការធុរកិច្ច

ខ. រចនាសម្ព័ន្ធចំណូល

**ផ្នែកទី ៣ - របាយការណ៍ហិរញ្ញវត្ថុដែលត្រូវបានធ្វើសវនកម្មដោយសវនករឯករាជ្យ**

**ផ្នែកទី ៤ - កិច្ចពិភាក្សា និងការវិភាគរបស់គណៈគ្រប់គ្រង**

ក. ទិដ្ឋភាពទូទៅនៃប្រតិបត្តិការ

ខ. កត្តាសំខាន់ៗដែលជះឥទ្ធិពលលើផលចំណេញ

គ. ការប្រែប្រួលសំខាន់ៗលើការលក់ និងប្រាក់ចំណូល

ឃ.ផលប៉ះពាល់នៃអត្រាប្តូររូបិយប័ណ្ណ អត្រាការប្រាក់ និងតម្លៃទំនិញ

ង. ផលប៉ះពាល់នៃអតិផរណា

ច. គោលនយោបាយសេដ្ឋកិច្ច សារពើពន្ធ និងសាច់ប្រាក់របស់រាជរដ្ឋាភិបាល

**ផ្នែកទី ៥ - ព័ត៌មានដែលចាំបាច់ផ្សេងទៀតសម្រាប់ការការពារវិនិយោគិន (ប្រសិនបើមានហត្ថលេខារបស់អភិបាលក្រុមហ៊ុន)**

PESTECH

## ផ្នែកទី ១ - ព័ត៌មានទូទៅពាក់ព័ន្ធនឹងក្រុមហ៊ុន

### ក. អត្តសញ្ញាណរបស់ក្រុមហ៊ុន

ឈ្មោះក្រុមហ៊ុនជាអក្សរខ្មែរ៖ **ផេសថិក (ខេមបូឌា)ម.ក**

ជាអក្សរឡាតាំង៖ **PESTECH (Cambodia) PLC**

លេខកូដស្តង់ដា៖ **PEPC**

អាសយដ្ឋាន៖ **ផ្ទះលេខ ៦ ផ្លូវលេខ ៥៨៨ សង្កាត់បឹងកក់ទី II ខណ្ឌទួលគោក ភ្នំពេញ ប្រទេសកម្ពុជា**

លេខទូរសព្ទ៖ **+៨៥៥ ២៣ ៨៨២ ១០៥** ទូរសារ៖ **+៨៥៥ ២៣ ៨៨២ ១០៦**

គេហទំព័រ៖ www.pestech.com.kh អ៊ីមែល៖ **info@pestech.com.my**

លេខវិញ្ញាបនបត្រចុះបញ្ជីពាណិជ្ជកម្ម៖ **00000៩៥៧** កាលបរិច្ឆេទ៖ **ថ្ងៃទី ៥ ខែកុម្ភៈ ឆ្នាំ ២០១០**

លេខអាជ្ញាប័ណ្ណអាជីវកម្ម៖ **៣២៦ Brk.DnS/ASN** ចេញដោយ៖ **MLMUPC**

កាលបរិច្ឆេទ៖ **ថ្ងៃទី ២០ ខែធ្នូ ឆ្នាំ ២០១៨**

សេចក្តីសម្រេចអនុញ្ញាត និងចុះបញ្ជីឯកសារផ្តល់ព័ត៌មានលេខ៖ **១៧១/២០ គ.ម.គ / ស.ស.រ.**

គ.ម.ក កាលបរិច្ឆេទ៖ **២២ ខែកក្កដា ឆ្នាំ២០២០**

អ្នកតំណាងរបស់ក្រុមហ៊ុន៖ **Paul Lim Pay Chuan**

### ខ. ប្រភេទអាជីវកម្ម

PCL ចូលរួមជាចម្បងនៅក្នុងការផ្តល់ដំណោះស្រាយផ្នែកវិស្វកម្ម និងបច្ចេកទេសនៃប្រព័ន្ធអគ្គិសនីគ្រប់ជ្រុងជ្រោយសម្រាប់៖

- ការរចនាប្លង់ ការធ្វើលទ្ធកម្ម ការសាងសង់ ការដំឡើង និងការដាក់ឲ្យប្រើប្រាស់អនុស្ថានីយ៍ HV និង EHV ខ្សែបញ្ជូនអគ្គិសនី HV និង EHV ព្រមទាំងប្រព័ន្ធខ្សែកាបអគ្គិសនីក្រោមដី សម្រាប់បញ្ជូន និងចែកចាយអគ្គិសនីផងដែរ
- ការដំណើរការ និងថែទាំ ("**O&M**") ខ្សែបញ្ជូនអគ្គិសនី និងអនុស្ថានីយ៍ និង
- ការធ្វើជំនួញសមាសធាតុ និងបរិក្ខារប្រព័ន្ធអគ្គិសនីដែលមានពាណិជ្ជសញ្ញាជារបស់ខ្លួនឯង និងមិនមែនជារបស់ខ្លួនឯង។

### គ.ព្រឹត្តិការណ៍សំខាន់ប្រចាំត្រីមាស

នៅថ្ងៃទី ១២ ខែ សីហា ឆ្នាំ ២០២០ PCLបានបញ្ចប់ការបោះផ្សាយមូលបត្រលើកដំបូង និងបានចុះបញ្ជីជួញដូរមូលបត្រនៅទីផ្សារមូលបត្រគោលនៃគណៈកម្មការមូលបត្រកម្ពុជា

PESTECH

## ផ្នែកទី ២ - ព័ត៌មានអំពីលទ្ធផលនៃការដំណើរការធុរកិច្ច

### ក. លទ្ធផលនៃការដំណើរការធុរកិច្ច

ដំណើរការនៃវិស្វកម្ម លទ្ធកម្ម ការសាងសង់ និង ការដាក់អោយតំណើរការ ("EPCC") កិច្ចសន្យា សំរាប់បណ្តាញអគ្គិសនី និងអនុស្ថានីយគឺជាកត្តាចូលរួមសំខាន់ចំពោះប្រាក់ចំណូលសម្រាប់រយៈពេលបីខែនៃឆ្នាំហិរញ្ញវត្ថុដែលបានបញ្ចប់នៅថ្ងៃទី ៣០ ខែកញ្ញា ២០២០ ដែលមានតម្លៃទឹកប្រាក់ចំនួន ៧១ ២៣៨ លានរៀល (ត្រីមាសទីមួយនៃឆ្នាំហិរញ្ញវត្ថុ ២០២០៖ ៤០ ៨៧៥ លានរៀល) ដែលស្មើនឹងប្រមាណ ៩៥,៧% (ត្រីមាសទីមួយនៃឆ្នាំហិរញ្ញវត្ថុ ២០២០៖៩៥,៧%) ធៀបនឹងប្រាក់ចំណូលសរុប។ ការបំពេញបន្ថែមនៃសេវាកម្ម EPCC របស់យើងដែលជាប្រតិបត្តិការនិងថែទាំដែលស្មើនឹងប្រមាណ ៣ ២១០ លានរៀល ឬ៤,៣% នៃប្រាក់ចំណូលសរុប (ត្រីមាសទីមួយនៃឆ្នាំហិរញ្ញវត្ថុ ២០២០៖ ១ ៨៣៤ លានរៀល ឬ៤,៣%)។

### ខ. រចនាសម្ព័ន្ធចំណូល

| ល.រ. | ប្រភពចំណូល | ត្រីមាសទីមួយ ឆ្នាំ ២០២១ | | ត្រីមាសទីមួយ ឆ្នាំ ២០២០ | |
|---|---|---|---|---|---|
| | | លានរៀល | ភាគរយ | លានរៀល | ភាគរយ |
| 1 | វិស្វកម្ម លទ្ធកម្ម ការសាងសង់ និង ការដាក់អោយតំណើរការ ("EPCC") កិច្ចសន្យា សំរាប់បណ្តាញអគ្គិសនី និងអនុស្ថានីយ | ៧១ ២៣៨ | ៩៥,៧ | ៤០ ៨៧៥ | ៩៥,7 |
| 2 | ប្រតិបត្តិការនិងថែទាំ | ៣ ២១០ | ៤,៣ | ១ ៨៣៤ | ៤,៣ |
| ប្រាក់ចំណូលសរុប | | ៧៤ ៤៤៨ | ១០០ | ៤២ ៧០៩ | ១០០ |

## ផ្នែកទី ៣ - របាយការណ៍ហិរញ្ញវត្ថុដែលត្រូវធ្វើសវនកម្មដោយសវនកររឯករាជ្យ

សូមយោងទៅតាមរបាយការណ៍ហិរញ្ញវត្ថុដែលបានភ្ជាប់មកជាមួយត្រូវបានធ្វើការត្រួតពិនិត្រឡើងវិញរួចរាល់ហើយដោយសវនកររឯករាជ្យ។

## ផ្នែកទី ៤ - ការពិភាក្សា និងការវិភាគរបស់គណៈគ្រប់គ្រង (“MD&A”)

### ក. ទិដ្ឋភាពទូទៅនៃប្រតិបត្តិការ

១. ការវិភាគចំណូល

ចំណូលសរុបសម្រាប់បីខែនៃរយៈពេលហិរញ្ញវត្ថុក្រោមការត្រួតពិនិត្រឡើងវិញ បានកត់ត្រាត្រឹម ៧៤ ៤៤៨ លានរៀល កើនឡើងចំនួន ៣១ ៧៣៩ លានរៀល ឬ ៧៤% បើប្រៀបធៀបទៅនឹងរយៈពេលបីខែនៃឆ្នាំហិរញ្ញវត្ថុមុន។ ការកើនឡើងភាគច្រើននេះ គឺបណ្តាលមកពីដំណាក់កាលនៃការអនុវត្តគម្រោងដែលមានស្រាប់។

២. ការវិភាគចំណូលតាមផ្នែក

ដំណើរការនៃវិស្វកម្ម លទ្ធកម្ម ការសាងសង់ និង ការដាក់អោយតំណើរការ ("EPCC") កិច្ចសន្យា សំរាប់បណ្តាញអគ្គិសនី និងអនុស្ថានីយគឺជាកត្តាចូលរួមសំខាន់ចំពោះប្រាក់ចំណូលសម្រាប់រយៈពេលបីខែសម្រាប់ឆ្នាំហិរញ្ញវត្ថុដែលបានបញ្ចប់នៅថ្ងៃទី ៣០ ខែកញ្ញា ២០២០ ដែលមានតម្លៃទឹកប្រាក់ចំនួន ៧១ ២៣៨ លានរៀល (ត្រីមាសទីមួយនៃឆ្នាំហិរញ្ញវត្ថុ ២០២០៖ ៤០ ៨៧៥ លានរៀល) ដែលស្មើនឹងប្រមាណ ៩៥,៧% (ត្រីមាសទីមួយនៃឆ្នាំហិរញ្ញវត្ថុ ២០២០៖៩៥,៧%) ធៀបនឹងប្រាក់ចំណូលសរុប។ ការបំពេញបន្ថែមនៃសេវាកម្ម EPCC របស់យើងដែលជាប្រតិបត្តិការនិងថែទាំដែលស្មើនឹងប្រមាណ ៣ ២១០ លានរៀល ឬ៤,៣% នៃប្រាក់ចំណូលសរុប (ត្រីមាសទីមួយនៃឆ្នាំហិរញ្ញវត្ថុ ២០២០៖ ១ ៨៣៤ លានរៀល ឬ៤,៣%)។

៣. ការវិភាគគម្លាតចំណេញដុល

ចំណេញដុលនៅក្នុងត្រីមាសបច្ចុប្បន្នក្រោមការត្រួតពិនិត្យឡើងវិញ ត្រូវបានកត់ត្រាត្រឹម ១៣% បើប្រៀបធៀបទៅនឹងត្រីមាសមុននៃឆ្នាំហិរញ្ញវត្ថុមុន ដែលមានចំនួន ៧% ដោយថយចុះចំនួន ៦%។ ចំណេញដុលនៃវឌ្ឍនភាពគម្រោងក្នុងត្រីមាសបច្ចុប្បន្នគឺស្ថិតនៅក្នុងការរំពឹងទុករបស់យើង។

៤. ការវិភាគចំណេញ/(ខាត)មុនបង់ពន្ធ

ខាតមុនបង់ពន្ធ ("LBT") នៅក្នុងត្រីមាសបច្ចុប្បន្នក្រោមការត្រួតពិនិត្យឡើងវិញ ត្រូវបានកត់ត្រាត្រឹម ១៨៨ លានរៀល ដោយបានប្រៀបធៀបទៅនឹងចំណេញដុលមុនបង់ពន្ធ ដែលមានចំនួន ១ ៨២២ លានរៀលនៃឆ្នាំហិរញ្ញវត្ថុមុន ដោយថយចុះចំនួន ២ ០១០ លានរៀល ឬ១១០% ។ ទោះបីជាមានការកើនឡើងនៃចំណេញដុលនៅក្នុងត្រីមាសបច្ចុប្បន្នក្រោមការត្រួតពិនិត្យឡើងវិញក៏ដោយ ក៏ការចំណាយហិរញ្ញប្បទានរបស់សម្ព័ន្ធមានចំនួន ៧ ០១១ លានរៀល ក្នុងត្រីមាសបច្ចុប្បន្នក្រោមការត្រួតពិនិត្យឡើងវិញដោយបង្ហាញថាមានភាពខ្ពស់ជាង បើប្រៀបធៀបទៅនឹងចំណាយហិរញ្ញប្បទានមានចំនួន ៤ ៥៤៩ លានរៀល ក្នុងត្រីមាសនៃឆ្នាំហិរញ្ញវត្ថុមុន។

៥. ការវិភាគចំណេញ/(ខាត)ក្នុងការិយបរិច្ឆេទ

ខាត ក្រោយពេលបង់ពន្ធ ("LAT") ត្រូវបានកត់ត្រាត្រឹម ១ ២៩៥ លានរៀល ដែលតំណាងឲ្យអវិជ្ជមានចំនួន ១,៧៤% នៃចំណូល។ ការកើនឡើងនៃការខាតក្នុងការិយបរិច្ឆេទនេះភាគច្រើន បណ្តាលមកពីសំវិធាន

PESTECH

ធនចំណាយលើពន្ធនៃពន្ធអប្បបរមា ១% នៃច្បាប់ស្តីពីសារពើពន្ធកម្ពុជា។ ការកើនឡើងនៃការខាតក្នុងការិយបរិច្ឆេទនេះ ក៏បណ្តាលមកពីបំណុលលើពន្ធពន្យាដែលកើតឡើងពីភាពខុសគ្នាជាបណ្តោះអាសន្នក្នុងការទទួលស្គាល់ការរំលោះតាមវិធានគណនេយ្យ និងការរំលោះពន្ធនៃច្បាប់ស្តីពីសារពើពន្ធកម្ពុជា។

## ខ. កត្តាសំខាន់ៗដែលប៉ះពាល់លើផលចំណេញ

កត្តាសំខាន់ៗដែលជះឥទ្ធិពលលើប្រាក់ចំណេញរបស់យើង ភាគច្រើនទទួលបានការរួមចំណែកពីវដ្តនៃគម្រោងជាបន្តបន្ទាប់ ក្នុងអំឡុងពេលនៃឆ្នាំដែលស្ថិតនៅក្រោមការត្រួតពិនិត្យឡើងវិញ។ នេះរួមបញ្ចូលដំណាក់កាលខុសៗគ្នានៃគម្រោង ដូចជា ដំណាក់កាលនៃការរចនាប្លង់ ការធ្វើផែនការ សំណង់ស៊ីវិល ការប្រគល់ ការតំឡើង និងការដាក់ឲ្យប្រើប្រាស់។ ដោយមានដំណើរការគម្រោងខុសៗគ្នានៅក្នុងពេលតែមួយ ផលប៉ះពាល់ទាំងនេះអាចត្រូវបានបន្ធូរបន្ថយតាមរយៈដំណាក់កាលខុសៗគ្នានៃគម្រោងនីមួយៗដែលធ្វើឲ្យកម្រិតលម្អៀងនៃប្រាក់ចំណេញដុលរបស់យើងស្ថិតនៅកម្រិតមធ្យម។

ចំណាយលើបរិក្ខារ ឬវត្ថុធាតុដើមដែលបានកើតឡើងនៅក្នុងការអនុវត្តគម្រោងរបស់យើង គឺអាស្រ័យលើការឡើងចុះនៃតម្លៃជាភាគរយរបស់វត្ថុធាតុដើម និងសម្ភារៈឧបភោគសម្រាប់ឆ្នាំដែលស្ថិតនៅក្រោមការត្រួតពិនិត្យឡើងវិញនោះនឹងជះឥទ្ធិពលដល់លទ្ធភាពក្នុងការទទួលបានប្រាក់ចំណេញរបស់ក្រុមហ៊ុន។ ទោះបីជាយ៉ាងណាក៏ដោយ បរិក្ខារ និងវត្ថុធាតុដើមដែលពាក់ព័ន្ធនឹងការងារនីមួយៗ ត្រូវបានទទួលយក និងបានទទួលថវិកា នៅក្នុងអំឡុងពេលដែលដំណាក់កាលនៃការដាក់សំណើត្រូវបានរាប់បញ្ចូលជាចំណាយសម្រាប់គម្រោងនីមួយៗ។ ការឡើងចុះនៃតម្លៃវត្ថុធាតុដើម ជាទូទៅត្រូវបានប្រគល់បន្តឲ្យរោងចក្រផលិតសមាសធាតុទាំងនោះជាអ្នកសំរេច ប្រសិនអាចធ្វើទៅបាន។

ភាពយឺតយ៉ាវណាមួយនៅក្នុងការប្រគល់បរិក្ខាររបស់ភាគីទីបីដែលនៅបរទេស អាចធ្វើឲ្យការអនុវត្តគម្រោងរបស់យើងមានភាពយឺតយ៉ាវដែរ និងបង្កើនចំណាយបន្ថែមដល់គម្រោង ដោយពុំមានក្នុងគម្រោងថវិកា។

## គ. ការប្រែប្រួលសំខាន់ៗលើការលក់ និងចំណូល

ចំណូលសរុបសម្រាប់រយៈពេលបីខែហិរញ្ញវត្ថុក្រោមការត្រួតពិនិត្យឡើងវិញ ត្រូវបានកត់ត្រាត្រឹម ៧៤ ៤៤៨ លានរៀល ដែលតំណាងឲ្យការកើនឡើងចំនួន ៣១ ៧៣៩ លានរៀល ឬ ៧៤% ដោយប្រៀបធៀបទៅនឹង ៤២ ៧០៩ លានរៀល ក្នុងរយៈពេលបីខែនៃឆ្នាំហិរញ្ញវត្ថុមុន។ ការកើនឡើងជាចម្បងបណ្តាលមកពីដំណាក់កាលនៃការអនុវត្តគម្រោងដែលមានស្រាប់។

## ឃ. ផលប៉ះពាល់នៃការប្តូររូបិយបណ្ណ អត្រាការប្រាក់ និងថ្លៃទំនិញ

ចំណូលពីការលក់ និងការទិញរបស់យើង ភាគច្រើនត្រូវបានធ្វើឡើងជាដុល្លារអាមេរិក។ ដូច្នេះ យើងមិនទទួលរងផលប៉ះពាល់យ៉ាងខ្លាំងក្លាពីការឡើងចុះនៃអត្រាប្តូររូបិយប័ណ្ណបរទេស នៅក្នុងអំឡុងឆ្នាំហិរញ្ញវត្ថុនេះទេ។ ការប្រឈមមុខនឹងអត្រាប្តូររូបិយប័ណ្ណបរទេស ភាគច្រើន បណ្តាលមកពីគោលបំណងនៅក្នុងការរាយការណ៍។

សម្រាប់ហានិភ័យនៃអត្រាការប្រាក់ PCL ប្រឈមមុខនឹងបម្រែបម្រួល តាមរយៈលិខិតូបករណ៍នៃអត្រាការប្រាក់អណ្តែត ពោលគឺ ការខ្ចីប្រាក់នៅក្នុងអត្រាអថេរ។

ពុំមានផលប៉ះពាល់ធ្ងន់ធ្ងរ ដែលបណ្តាលមកពីការឡើងចុះនៃតម្លៃទំនិញនោះទេ។

### ង. ផលប៉ះពាល់នៃអតិផរណា

ការចំណាយសម្រាប់អាជីវកម្មរបស់យើង គឺដោយសារផលប៉ះពាល់នៃអតិផរណា ដែលមានចំនួនប្រហែល ១៥% នៃ ចំណូលរបស់យើង។ ទោះបីជាយ៉ាងណាក៏ដោយ អតិផរណានៅក្នុងប្រទេសកម្ពុជាមានចំនួន ៣% (គិតត្រឹមខែកញ្ញា ឆ្នាំ ២០២០ ប្រភព:ភ្នំពេញប៉ុស្តិ៍ NBC អត្រាអតិផរណានៅតែមាន៣% នោះបីសេដ្ឋកិច្ចធ្លាក់ចុះក៏ដោយ) ដែលបានបង្កផលប៉ះពាល់ប្រហែល 0.៤៥% តែប៉ុណ្ណោះ ចំពោះប្រាក់ចំណេញរបស់យើង។ រាល់ចំណាយប្រតិបត្តិការទាំងអស់ មានតម្លៃថេរ នៅក្នុងរយៈពេលនៃកិច្ចសន្យាទាំងមូល។ ក្រៅពីការលើកឡើងខាងលើ ពុំមានផលប៉ះពាល់សំខាន់ៗផ្សេងទៀត ដែលបណ្តាលមកពីអតិផរណានោះទេ។

### ច. គោលនយោបាយសេដ្ឋកិច្ច សារពើពន្ធ និងរូបិយវត្ថុរបស់រាជរដ្ឋាភិបាល

ពុំមានបម្រែបម្រួលសំខាន់ៗនៅក្នុងគោលនយោបាយសេដ្ឋកិច្ច/សារពើពន្ធ/សាច់ប្រាក់របស់រាជរដ្ឋាភិបាល ឬកត្តានានាដែលមានផលប៉ះពាល់យ៉ាងធ្ងន់ធ្ងរចំពោះលទ្ធផលហិរញ្ញវត្ថុ នៅក្នុងអំឡុងឆ្នាំនេះទេ។

PESTECH

## ផ្នែកទី ៥ - ព័ត៌មានដែលចាំបាច់ផ្សេងទៀតសម្រាប់ការការពារវិនិយោគិន

ពុំមានព័ត៌មានដែលចាំបាច់ផ្សេងទៀតសម្រាប់ការការពារវិនិយោគិន។

PESTECH

**ហត្ថលេខារបស់អភិបាលក្រុមហ៊ុន**

(នឹងត្រូវបានចុះហត្ថលេខាដោយប្រធានក្រុមប្រឹក្សាភិបាល រឺយ៉ាងតិចដោយប្រធានប្រតិបត្តិចំនួនពីររូប)

បានអាន និងឯកភាព៖

ហត្ថលេខា

ឈ្មោះ៖ Paul Lim Pay Chuan

មុខតំណែង៖ **ប្រធានក្រុមប្រឹក្សាភិបាល**

11 NOV 2020